ទំនុកដំកើង ៤៤:៤-៤៥:១៧

សូមយើងស្តាប់សម្លេងសាសន៍អ៊ីស្រាអែល ស្រែកអំពាវនាវរកព្រះមហាក្សត្រ ដែលយាងមកសង្គ្រោះគេអោយរួចពីគ្រោះមហាវេទនា។

**ឱព្រះអង្គអើយ ទ្រង់ជាមហាក្សត្រនៃទូលបង្គំ សូមបង្គាប់ឱ្យមាន សេចក្តីសង្គ្រោះដល់ពួកយ៉ាកុប (ទំនុកដំកើង៤៤:៤)។**

លោកយ៉ាកុប យើងឃើញសម្តែងនៅក្នុងខខាងលើ ជាលោកយ៉ាកុបដែលត្រូវជាឪពុកនៃសាសន៍អ៊ីស្រាអែល។ "ឱព្រះអង្គអើយ ទ្រង់ជាមហាក្សត្រនៃទូលបង្គំ" ព្រះអម្ចាស់យេស៊ូវទ្រង់ជាមហាក្សត្រសម្រាប់សាសសន៍អ៊ីស្រាអែល។ ទ្រង់យាងត្រឡប់មកវិញជាលើកទីពីរ ដើម្បីរំដោះរាស្ត្រទ្រង់អោយរួចពីសេចក្តីទុក្ខ ដែលគេកំពុងទ្រាំទ្រក្នុងគ្រាគេរស់ឆ្លងកាត់គ្រោះមហាវេទនា។ សេចក្តីពិតនេះ អាចយកមកអនុវត្តនៅក្នុងជីវិតរបស់យើងបានដែរ។ ប៉ុន្តែ យើងចាំបាច់ត្រូវយល់សេចក្តីដែលសម្តែងនៅក្នុងគម្ពីរទំនុកដំកើងត្រង់ចំណុចនេះ ទើបយើងឃើញខ្លឹមសារយ៉ាងជ្រាលជ្រៅសម្រាប់យកមកអនុវត្តនៅក្នុងជីវិតរបស់យើង។

**[៥]យើងខ្ញុំនឹងច្រានផ្តួលពួកខ្មាំងសត្រូវ ដោយសារទ្រង់ ហើយនឹង**

**ជាន់ឈ្លីពួកអ្នក ដែលលើកគ្នាទាស់នឹងយើងខ្ញុំ ដោយនូវព្រះនាមទ្រង់ ៦ ដ្បិតទូលបង្គំនឹងមិនពឹងធ្នូរបស់ទូលបង្គំទេ ហើយដាវទូលបង្គំក៏មិនជួយសង្គ្រោះទូលបង្គំដែរ (ទំនុកដំកើង៤៤:៥-៦)។**

ក្នុងគ្រាសាសន៍អ៊ីស្រាអែលឆ្លងកាត់គ្រាមហាវេទនា សំណល់នៃសាសន៍អ៊ីស្រាអែលអំពាវនាវសូមដល់ព្រះជាម្ចាស់ អោយទ្រង់ធ្វើការសងសឹក។ សូមចាំថា សាសន៍អ៊ីស្រាអែលរស់នៅក្រោមបន្ទុកក្រឹត្យវិន័យ។ ដូច្នេះ គេមានសិទ្ធិអំពាវនាវទូលសូមដល់ព្រះអង្គអោយធ្វើការនោះបាន។

ចុះចំពោះយើង ដែលរស់នៅសម័យសព្វថ្ងៃនេះវិញ តើមានសិទ្ធិទូលសូមអោយព្រះជាម្ចាស់សងសឹកដូចសាសន៍អ៊ីស្រាអែលបានដែរឬទេ? ព្រះគម្ពីរបង្រៀនដល់យើងថា យើងមិនគ្រាន់តែមិនសងសឹកចំពោះសត្រូវតែប៉ុណ្ណោះទេ យើងត្រូវអធិស្ឋានព្រមទាំងស្រឡាញ់ដល់សត្រូវរបស់យើងថែមទៀតផង។ ករណីយកិច្ចនេះ យើងពិបាកអនុវត្តណាស់។ ប៉ុន្តែ ទោះជាពិបាកយ៉ាងនោះក៏ដោយ យើងមិនត្រូវសងសឹកចំពោះសត្រូវរបស់យើងទេ។ ផ្ទុយទៅវិញ យើងត្រូវផ្ទេរការដែលសត្រូវធ្វើទុក្ខដល់យើង ដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ គម្ពីររ៉ូម១២:១៩ បង្រៀនយើងថា "ឱពួកស្ងួនភ្ងាអើយ កុំឱ្យសងសឹកឡើយ ចូរថយចេញពីសេចក្តីកំហឹងទៅ ដ្បិតមានសេចក្តីចែងទុកមកថា "ព្រះអម្ចាស់ ទ្រង់មានបន្ទូលថា ការសងសឹក នោះស្រេចនឹងអញ អញនឹងសងដល់គេ"។ មានមនុស្សអាក្រក់ជាច្រើនខំប្រឹងអស់មធ្យោបាយ ដើម្បីប្រឆាំងនឹងគ្រូអធិប្បាយ និង

បង្ហាត់បង្រៀនព្រះបន្ទូលរបស់ព្រះជាម្ចាស់។ អ្នកទាំងនោះចង់សម្រេចក្តីដោយខ្លួនឯង មិនព្រមផ្ទេរការសងសឹកដល់ព្រះជាម្ចាស់ទេ។ ចំពោះជនណាដែលខំប្រឹងធ្វើជាឧបសគ្គដល់បាវបម្រើរបស់ព្រះជាម្ចាស់ ជននោះភ្លេចគិតថា ខ្លួនកំពុងឈរទាស់ទទឹងនឹងព្រះជាម្ចាស់ផ្ទាល់។ ដោយហេតុនេះហើយ បានជាលោកអ្នកត្រូវប្រយ័ត្នខ្លួនផង បើលោកអ្នករិះគន់ដល់គ្រូគង្វាលរបស់លោកអ្នក។ បើការរិះគន់នោះមានភ័ស្តុតាងគ្រប់គ្រាន់ រាប់ថាជារឿងពិត ចូរធ្វើការនោះដោយស្រឡាញ់ចុះ។ ប៉ុន្តែ បើគ្រាន់តែជារឿងចោទប្រកាន់ ឬជាការច្រណែននិន្ទាទេ លោកអ្នកពិតជាធ្វើខុសចំពោះលោកហើយ។ គ្រូគង្វាលដែលបង្ហាត់បង្រៀនព្រះបន្ទូលរបស់ព្រះជាម្ចាស់ ជាជនដែលព្រះជាម្ចាស់តែងតាំងធ្វើជាតំណាងរបស់ទ្រង់នៅលើផែនដី។ បើលោកអ្នកដើរនិយាយសំអុយឈ្មោះគាត់ លោកអ្នកកំពុងបន្ទាបបន្ថោកព្រះនាមព្រះជាម្ចាស់ជាពិតប្រាកដ។ នៅក្នុងគ្រួសារគ្រីស្ទបរិស័ទខ្លះ បុត្រធីតាមានចិត្តធុញទ្រាន់នឹងក្រុមជំនុំ ដូចជាមានការធុញទ្រាន់នឹងកិច្ចការងាររបស់គ្រីស្ទបរិស័ទដែរ។ មូលហេតុចម្បងបង្អស់គឺ ឪពុកម្តាយរបស់គេមានចិត្តច្រណែននិន្ទាជាមួយគ្រូគង្វាលរបស់ខ្លួន។ មួយថ្ងៃៗ ពេលគេពិសារបាយ គេធ្វើម្ហូបចៀនសាច់គ្រូគង្វាលទទួលទាន។ ពេលឪពុកម្តាយរៀបចំធ្វើម្ហូបអាហារ គេនាំគ្នាពន្លាត់ស្បែកគ្រូគង្វាលបណ្តើរ ដាំស្លរបណ្តើរ។ កូនចៅរបស់គេឮរឿងនោះ គេធុញទ្រាន់ជាមួយនឹងឪពុកម្តាយយ៉ាងខ្លាំង គេមិនចង់ចូលរួមក្នុងកិច្ចការក្រុមជំនុំទៀត។ បើលោកអ្នកជាជនប្រភេទនោះ សូមឈប់ប្រព្រឹត្តការអាក្រក់នោះតទៅទៀត ដ្បិតការនិយាយទាស់ទទឹងនឹងគ្រូអធិប្បាយព្រះបន្ទូលរបស់ព្រះជាម្ចាស់ ជាការខុសឆ្គងយ៉ាងខ្លាំងក្រៃលែង។

បើលោកអ្នកយល់ថា គ្រូរូបនោះធ្វើអំពើអ្វីមួយខុសឆ្គង សូមលោកអ្នកចូលទៅព្រះជាម្ចាស់អោយទ្រង់ធ្វើអន្តរាគមន៍ចុះ។ សូមកុំអោយដើរនិយាយប៉ប៉ាច់បប៉ោចដូចបាយពុះលើចង្ក្រានមានភ្លើងអោយសោះ។ ព្រះជាម្ចាស់អាចសម្រេចការសងសឹកបាន ដោយលោកអ្នកមិនចាំបាច់ធ្វើការសងសឹកដោយខ្លួនឯងទេ។

នៅពេលសាសន៍អ៊ីស្រាអែលឆ្លងកាត់គ្រាមហាវេទនា គេទ្រាំទ្រការរងទុក្ខលើសពីពាក្យមនុស្សអាចពណ៌នា។ ពួកសត្រូវលើកគ្នាទាស់ជាមួយនឹងសាសន៍អ៊ីស្រាអែលទាំងម៉ឺនទាំងសែន។ គម្ពីរដានីយ៉ែល៧:២៥ សម្តែងថា "ស្តេចនោះនឹងពោលពាក្យទាស់នឹងព្រះដ៏ខ្ពស់បំផុត ហើយនឹងធ្វើទុក្ខបៀតបៀនដល់ពួកបរិសុទ្ធនៃព្រះដ៏ខ្ពស់បំផុតដែរ ព្រមទាំងគិតបំផ្លាស់ពេលកំណត់ នឹងច្បាប់ផង ហើយគេនឹងត្រូវប្រគល់ទៅក្នុងកណ្តាប់ដៃនៃស្តេចនោះ នៅ១ខួប ២ខួប ហើយកន្លះខួប"។ សាសន៍អ៊ីស្រាអែល ជារាស្ត្ររបស់ព្រះជាម្ចាស់ រស់នៅក្រោមការគ្រប់គ្រងរបស់ជនទទឹងនឹងព្រះគ្រីស្ត។ ជននោះលើកទ័ព ពីគ្រប់ទិសទី ដើម្បីវាយសន្ធប់មកលើរាស្ត្ររបស់ព្រះអង្គ។ ព្រះជាម្ចាស់ហាមមិនអោយគេតបតជាមួយនឹងជនទាំងនោះទេ។ ម្យ៉ាងវិញទៀត រាស្ត្របរិសុទ្ធរបស់ព្រះបដិសេធ មិនទទួលសញ្ញាដែលជនទទឹងនឹងព្រះគ្រីស្ត អោយពាក់នៅលើខ្លួន។ ដោយសារមូលហេតុនោះ គេសម្លាប់រាស្ត្របរិសុទ្ធរបស់ព្រះជាម្ចាស់ជាច្រើនពាន់ ច្រើនម៉ឺននាក់។ ក្នុងកាលៈទេសៈបែបនេះ រាស្ត្ររបស់ព្រះត្រូវអំពាវនាវសូមដល់ព្រះជាម្ចាស់អោយទ្រង់យាងមកជួយដល់គេផង។ គ្រាមហាវេទនា ជាគ្រាដែលមានភាពងងឹតយ៉ាងខ្លាំងនៅក្នុងប្រវត្តិសាស្ត្រនៃសាកលលោក។

**យើងខ្ញុំត្រូវគេសំឡាប់ ជាដរាបរាល់ថ្ងៃដោយព្រោះទ្រង់ ហើយក៏រាប់ទុកដូចជាចៀមដែលសំរាប់សំឡាប់ (ទំនុកដំកើង៤៤:២២)។**

បទគម្ពីរខាងលើ មិនសម្តែងពីក្រុមជំនុំរបស់ព្រះជាម្ចាស់ទេ។ បច្ចុប្បន្ននេះមានការបៀតបៀនដល់ក្រុមជំនុំរបស់ព្រះជាម្ចាស់ខ្លះៗដែរ។ ប៉ុន្តែ ការបៀតបៀនដ៏តិចតួចនេះ មិនអាចប្រៀបផ្ទឹមទៅនឹងគ្រាមហាវេទនា ដែលសំណល់នៃសាសន៍អ៊ីស្រាអែលត្រូវឆ្លងកាត់ឡើយ។ ខ្ញុំចង់អោយលោកអ្នកបងប្អូនយល់អោយបានច្បាស់ពីដំណើរនេះ។ គ្រាវេទនាមិនមែនជាគ្រាសព្វថ្ងៃនេះទេ ទោះបីក្រុមជំនុំរបស់ព្រះជាម្ចាស់រងទុក្ខខ្លាំងក្លាយ៉ាណាក៏ដោយ។

**ឱព្រះអម្ចាស់អើយ សូមទ្រង់តើនឡើង ហេតុអ្វីបានជាទ្រង់នៅផ្ទំលក់ សូមទ្រង់តើនឡើង កុំបោះបង់ចោលយើងខ្ញុំជាដរាបឡើយ (ទំនុកដំកើង៤៤:២៣)។**

នៅពេលឆ្លងកាត់គ្រាវេទនា សាសន៍អ៊ីស្រាអែលខ្លះយល់ថា ព្រះជាម្ចាស់ទ្រង់ផ្ទំលក់។ ព្រះជាម្ចាស់មិនដែលផ្ទំលក់ម្តងណាទាល់តែសោះ។ ប៉ុន្តែ ដោយសាររាស្ត្ររបស់ព្រះជាម្ចាស់ឆ្លងកាត់ការវេទនាខ្លាំងពេក បានជាគេចេះតែនាំគ្នាយល់ថា ព្រះជាម្ចាស់ទ្រង់ផ្ទំលក់បាត់ទៅហើយ។ នៅក្នុងប្រវត្តិសាស្ត្ររបស់មនុស្សលោក ជាពិសេស

នៅចន្លោះគ្រាសញ្ញាចាស់ និងគ្រាសញ្ញាថ្មី មានចលនាមួយហៅថាចលនាម៉ាក់កាប៊ី។ ចលនាម៉ាក់កាប៊ី បង្កើតឡើងដោយសាសន៍អ៊ីស្រាអែល ទាមទារសូមអោយមាននគររបស់ខ្លួនឡើងវិញ តាមការតស៊ូផ្នែកនយោបាយ។ នៅពេលនោះ សាសន៍ដទៃជាអ្នកគ្រប់គ្រងលើសាសន៍អ៊ីស្រាអែល បានចាប់ពួកម៉ាក់កាប៊ីសម្លាប់ ព្រមទាំងធ្វើទុក្ខបុកម្នេញយ៉ាងខ្លាំង ហួសពីពាក្យមនុស្សអាចពណ៌នា។ ប៉ុន្តែ ទោះមានការលំបាកយ៉ាងដូច្នេះក៏ដោយ ជំនាន់ពួកម៉ាក់កាប៊ីរស់នៅ ក៏មិនមែនជាគ្រាវេទនាដែរ។ ព្រះជាម្ចាស់មិនដែលផ្ដលក់ ឬរលីវម្ដងណាសោះ។ យើងមិនចាំបាច់ដាស់ព្រះជាម្ចាស់ អោយទ្រង់ភ្ញាក់ពីតើនដែរ ពីព្រោះព្រះអង្គមិនដែលផ្ទំមួយវិនាទីណាឡើយ។ ប៉ុន្តែរឿងនេះ ជារឿងពិត ពេលសំណល់សាសន៍អ៊ីស្រាអែល ត្រូវរស់នៅឆ្លងកាត់គ្រាវេទនា។ គេអំពាវនាវសូមអោយព្រះជាម្ចាស់តើនឡើងទតមើលទុក្ខលំបាករបស់គេ។ ព្រះជាម្ចាស់ពិតជាយាងមករំដោះគេអោយរួចពីទុក្ខលំបាកនោះមែន។ ព្រះជាម្ចាស់មិនដែលបោះបង់ចោលរាស្ត្ររបស់ព្រះអង្គ ឬភ្លេចគេស្ងួនឲ្យឈឹងទេ។

**[២៤]ហេតុអ្វីបានជាទ្រង់លាក់ព្រះភក្ត្រ ហើយភ្លេចសេចក្ដីវេទនា នឹង**
**សេចក្ដីទុក្ខលំបាករបស់យើងខ្ញុំ [២៥]ដ្បិតព្រលឹងនៃយើងខ្ញុំបានត្រូវ**
**ឱនដល់ធូលីដីហើយ ខ្លួនប្រាណនៃយើងខ្ញុំក៏ជាប់នៅដីដែរ [២៦]សូម**
**ទ្រង់តើនឡើងជួយយើងខ្ញុំ ហើយលោះយើងខ្ញុំ ដោយយល់ដល់**
**សេចក្ដីសប្បុរសរបស់ទ្រង់ផង (ទំនុកដំកើង៤៤:២៤-២៦)។**

ក្នុងគ្រាមហាទុក្ខ សាសន៍អ៊ីស្រាអែលអំពាវនាវទូលសូមដល់ព្រះជាម្ចាស់អោយយាងមកប្រោសលោះគេ ដោយយល់ដល់ព្រះនាមបរិសុទ្ធរបស់ទ្រង់។ សេចក្ដីអំពាវនាវបែបនោះ ជាសេចក្ដីអំពាវនាវសូមអោយព្រះអម្ចាស់រកយុត្តិធម៌អោយគេផង។

# ជំពូក ៤៥

***ប្រធានបទ** ព្រះគ្រីស្ទយាងមកតាំងរាជ្យទ្រង់នៅផែនដី*

គម្ពីរទំនុកដំកើងជំពូក៤៥ ជាគម្ពីរបទទំនាយពីព្រះអង្គសង្គ្រោះ។ គម្ពីរនេះត្រូវយកមកប្រើនៅក្នុងគម្ពីរហេព្រើរជាញឹកញាប់។ ម្យ៉ាងវិញទៀត គម្ពីរទំនុកដំកើងជំពូក៤៥ ជាទំនុកសម្រាប់ជាសេចក្តីបង្រៀនផងដែរ។ អ្នកកត់ត្រាបទគម្ពីរនេះជាពួកកូនចៅលោកកូរេ។ ទំនុករបស់កូនចៅកូរេ ដែលសរសេរនៅក្នុងគម្ពីរទំនុកដំកើងជំពូក៤៥ សរសេរតាមបទផ្កាឈូក សម្រាប់មេភ្លេង។ បទនេះជាចម្រៀងពីសេចក្តីស្រឡាញ់។ នៅក្នុងអត្ថបទនេះ ព្រះមហាក្សត្រ ពោលគឺព្រះអង្គសង្គ្រោះនាមព្រះអម្ចាស់យេស៊ូវគ្រីស្ទ។

ម្យ៉ាងវិញទៀត គម្ពីរទំនុកដំកើងជំពូក៤៥ សម្តែងពីការយាងត្រឡប់មកវិញជាលើកទីពីរនៃអង្គព្រះគ្រីស្ទ។ ក្នុងពេលដែលសំណល់នៃសាសន៍អ៊ីស្រាអែលឆ្លងកាត់គ្រាមហាវេទនា ព្រះអម្ចាស់យេស៊ូវយាងមកជាលើកទីពីរ ដើម្បីដោះគេអោយរួចពីទុក្ខលំបាកនោះ។ សេចក្តីដដែលនេះ មានចែងក្នុងគម្ពីរវិវរណៈជំពូក១៩។ ចំណែកព្រះអម្ចាស់យេស៊ូវ ទ្រង់មានបន្ទូលពីព្រះឱស្ឋទ្រង់ផ្ទាល់ដែរក្នុងគម្ពីរម៉ាថាយ២៤:២៩-៣០។ ការយាងត្រឡប់មកវិញជាលើកទីពីរនៃព្រះអម្ចាស់យេស៊ូវ ជាសេចក្តីសង្ឃឹមដ៏ធំបំផុត

សម្រាប់ពិភពលោកយើងនេះ។

**ចិត្តរបស់ខ្ញុំពេញហៀរដោយសេចក្ដីដ៏ល្អ គឺខ្ញុំនិយាយពីសេចក្ដីដែលខ្ញុំបាននិពន្ធពីដំណើរមហាក្សត្រ អណ្ដាតខ្ញុំជាស្លាបប្រកានៃអ្នកតែងរឿងយ៉ាងជំនាញ (ទំនុកដំកើង៤៥:១)។**

“ចិត្តរបស់ខ្ញុំពេញហៀរដោយសេចក្ដីល្អ” មានន័យថា ចិត្តរបស់អ្នកកត់ត្រាគម្ពីរទំនុកដំកើងជំពូក៤៥ មានពេញទៅដោយសេចក្ដីរីករាយសាទរ។ ដោយសារមូលហេតុនោះ ដៃលោកកត់ត្រាមិនទាន់ពាក្យដែលចេញពីបបូរមាត់របស់លោក។ ជួនកាលយើងមានបទពិសោធន៍បែបនោះ ពិសេសពេលយើងសប្បាយ យើងពិបាកសរសេរខ្លាំងណាស់ ពីព្រោះដៃកត់មិនទាន់មាត់។ ចំពោះកូនចៅលោកកូរេដែលបានកត់ត្រាព្រះបន្ទូលព្រះអង្គក្នុងគម្ពីរទំនុកដំកើងជំពូក៤៥ គេអាចគ្រប់គ្រងចិត្តរបស់គេបាន។ ទោះបីសប្បាយយ៉ាងណាក៏ដោយ គេអាចកត់ត្រាព្រះបន្ទូលព្រះទុកជាភាសាមនុស្សជាតិអោយយើងបានឃើញមកទល់ពេលសព្វថ្ងៃ។

## ចេស្ដានៃព្រះអង្គសង្គ្រោះ

**ទ្រង់ព្រះករុណាល្អវិសេសជាងអស់ទាំងពួកមនុស្ស ព្រះរឹមទ្រង់ប្រកបដោយព្រះគុណ ហេតុនោះបានជាព្រះបានប្រទានពរដល់ទ្រង់ជាដរាបតទៅ (ទំនុកដំកើង៤៥:២)។**

បទគម្ពីរខាងលើ សម្តែងពីតួអង្គព្រះយេស៊ូវគ្រីស្ទ។ សាវ័កប៉ុលមានប្រសាសន៍ពីអង្គព្រះយេស៊ូវគ្រីស្ទ ក្នុងគម្ពីរ២កូរិនថូស៣:១៨ដែរថា "ហើយយើងរាល់គ្នាទាំងអស់ដែលកំពុងតែរំពឹងមើលសិរីល្អព្រះអម្ចាស់ ទាំងមុខទទេ ដូចជាឆ្លុះមើលទ្រង់ក្នុងកញ្ចក់ យើងកំពុងតែផ្លាស់ប្រែទៅ ឱ្យដូចជារូបឆ្លុះនោះឯង ពីសិរីល្អទៅដល់សិរីល្អ គឺដោយសារព្រះអម្ចាស់ដ៏ជាព្រះវិញ្ញាណ"។ លោកអ្នកបងប្អូនអើយ យើងចាំបាច់ត្រូវសម្លឹងមើលព្រះភក្ត្រព្រះយេស៊ូវអោយបានរៀងរាល់ថ្ងៃ ក្នុងជីវិតរបស់យើង។

ក្នុងគម្ពីរទំនុកដំកើងជំពូក៤៥នេះ យើងឃើញថា ព្រះអម្ចាស់យេស៊ូវយាងមកមិនមែនជាអង្គសង្គ្រោះទៀតទេ។ ទ្រង់យាងមកជាមហាក្សត្រលើអស់ទាំងក្សត្រនានា។

**ឱព្រះករុណាដ៏មានឥទ្ធិឫទ្ធិអើយ សូមក្រវាត់ដាវជាប់នៅត្រគាកទ្រង់ ទុកជាគ្រឿងលំអ នឹងសក្តិយសនៃទ្រង់ផង (ទំនុកដំកើង៤៥:៣)។**

រូបភាពខាងលើរៀបរាប់ពីអង្គព្រះយេស៊ូវថាជាព្រះមហាក្សត្រ ពោលគឺព្រះ

អង្គមិនមែនជាអង្គសង្គ្រោះដល់មនុស្សលោកទៀតទេ។ ចំពោះសាសន៍អ៊ីស្រាអែលគេសង្ឃឹមថា ព្រះអម្ចាស់នៃគេដែលទ្រង់យាងមកជាក្សត្រគ្រប់គ្រង។ ទ្រង់យាងមកទ្រង់គ្រឿងដោយដាវក្រវាត់អង្គ។ កាលព្រះអម្ចាស់យេស៊ូវយាងមកលើកទី១ ពោលគឺពីរពាន់ឆ្នាំកន្លងទៅ ព្រះអង្គយាងមកឥតមានដាវក្រវាត់អង្គ។ បើលោកអ្នកមិនទាន់ភ្លេចនៅឡើយ ពេលគេមកចាប់ព្រះអម្ចាស់យេស៊ូវ សិស្សរបស់ទ្រង់បានហូតដាវកាប់ដាច់ស្លឹកត្រចៀកបាវបម្រើរបស់សម្ដេចសង្ឃមួយរូប។ ព្រះអម្ចាស់យេស៊ូវមានបន្ទូលទៅកាន់ពួកសិស្សរបស់ទ្រង់ថា "...ចូរស៊កដាវអ្នកទៅក្នុងស្រោមវិញទៅ ដ្បិតអស់អ្នកដែលយកដាវ នោះត្រូវស្លាប់ដោយដាវដែរ" (ម៉ាថាយ២៦:៥២)។ ក្នុងជំនាន់យើងរស់នៅមនុស្សលោកតែងគិតថាមានស្ដេចមួយអង្គ យាងមកគ្រប់គ្រងពិភពលោកដោយគ្មានដាវ។ ប៉ុន្តែ គម្ពីរទំនុកដំកើង២:៩ព្រះអម្ចាស់មានបន្ទូលថា "ឯងនឹងបំបាក់បំបែកគេដោយដំបងដែក ព្រមទាំងបោកកំទេចគេទៅ ដូចជាភាជនៈរបស់ជាងស្មូន"។ ទំនុកដំកើងជំពូក២ បរិយាយពីព្រះអម្ចាស់យេស៊ូវគ្រីស្ទ យាងមកលើពិភពលោកយើងនេះជាលើកទីពីរ។ បទគម្ពីរនេះ មានបរិយាយជាច្រើនលើកនៅក្នុងព្រះគម្ពីរវិវរណៈ។ នៅពេលព្រះអម្ចាស់យេស៊ូវយាងត្រឡប់មកវិញជាលើកទីពីរ ពិភពលោកទាំងមូល នាំគ្នាបះបោរទាស់នឹងព្រះអង្គ។ ពិភពលោកសម័យនោះគ្រប់គ្រងដោយជនមានអំណាចមួយរូប ដែលព្រះគម្ពីរហៅថាអាទទឹងនឹងព្រះគ្រីស្ទ។ ជននោះសោយរាជ្យដោយអះអាងថាខ្លួនជាព្រះគ្រីស្ទ។ នៅពេលនោះ ទាំងសាសន៍អ៊ីស្រាអែលសេសសល់ ទាំងសាសន៍ដទៃដែលកោតខ្លាចដល់ព្រះជាម្ចាស់ សុទ្ធតែត្រូវទទួលការធ្វើទុក្ខបុកម្នេញពីជនទទឹងនឹង

ព្រះគ្រីស្ទ ក៏ដូចជាបក្សពួកដែលគ្រប់គ្រងសកលលោកសម័យនោះដែរ។

ជំពូក៤៥:២ មានឃ្លាមួយសម្តែងថា "...ព្រះរឹមទ្រង់ប្រកបដោយព្រះគុណ"។ ចំណុចនេះមានន័យថា ព្រះអង្គយាងមកប្រកបដោយព្រះគុណផង ប្រកបដោយសេចក្តីជំនុំជំរះផង។ យើងត្រូវស្គាល់រឿងនេះអោយបានពិតប្រាកដ ដ្បិតមិនមែនជារឿងព្រេងទេ។ ពេលព្រះអម្ចាស់យាងមកជាលើកទីពីរ ព្រះអង្គយាងមកជាមហាក្សត្រគ្រប់គ្រងផែនដី ពោលគឺព្រះអង្គយាងមកដើម្បីបង្ក្រាបមឹកទាំងប្រាំបីទិស។ ឯមឹកទាំងប្រាំបីទិសនោះទៀតសោត គឺជាពពួកមនុស្សលោកដែលនាំគ្នាបះបោរទាស់នឹងរាជ្យចេស្តារបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។

> **រួចជិះទៅ ដោយឥទ្ធិឫទ្ធិរបស់ទ្រង់ មានទាំងជ័យជំនះផង ដើម្បីការពារសេចក្តីពិត សេចក្តីសុភាព នូវសេចក្តីសុចរិត នោះព្រះហស្តស្តាំនៃទ្រង់នឹងបង្រៀនទ្រង់ ពីការដែលគួរកោតខ្លាច (ទំនុកដំកើង៤៥:៤)។**

សូមលោកអ្នកពិចារណាអោយបានច្បាស់ ពីសេចក្តីដែលបង្កប់នៅក្នុងខគម្ពីរខាងលើ។ ពេលព្រះអម្ចាស់យេស៊ូវយាងមកជាលើកទីពីរ ទ្រង់យាងមកគ្រប់គ្រងសកលលោកនេះដោយមានជ័យជំនះ។ ឯរាជ្យរបស់ព្រះអង្គ ត្រូវទ្រទ្រង់ដោយធម៌ត្រៃសិលាទីមួយ សេចក្តីពិត១ សេចក្តីសុភាព១ និងសេចក្តីសុចរិត១។ នៅលើលោកនេះ តើមាន

អ្នកដឹកនាំនយោបាយណាមួយ គ្រប់គ្រងនគរដោយធម៌ទាំងបីនេះដែរឬទេ? បើនិយាយពីបេក្ខជនឈរឈ្មោះអោយយើងបោះឆ្នោតវិញ គេខ្វាចសេចក្តីពិត។ គេបើកមាត់ឡើងសម្តែងពីកិរិយាកាចសាហាវនៅក្នុងចិត្តរបស់គេ។ គេរាប់អាវកខ្វក់របស់គេថាជាសេចក្តីសុចរិត។ អ្នកនយោបាយដែលគ្រប់គ្រងពិភពលោកកន្លងមក ច្រើនតែជាមនុស្សដែលខំអោយគេបោះឆ្នោត ដើម្បីធ្វើការអាក្រក់តែម្យ៉ាងប៉ុណ្ណោះ។ ពិភពលោកយើងនេះមានភ័ព្វវាសនាអាក្រក់ណាស់ ដ្បិតអ្នកដឹកនាំនយោបាយតែងគ្រប់គ្រងដោយខ្វះសេចក្តីពិត ខ្វះសេចក្តីសុភាព និងខ្វះសេចក្តីសុចរិត។ នៅលើលោកនេះ គ្មានប្រធានាធិបតីណា គ្មានអ្នកដឹកនាំនយោបាយណា គ្មានអ្នកគ្រប់គ្រងអំណាចផ្តាច់ការណា ឬក្សត្រណាមួយដែលឡើងគ្រងរាជ្យប្រកបដោយធម៌ទាំងបី គឺសេចក្តីពិត១ សេចក្តីសុភាព១ និងសេចក្តីសុចរិត១។ ចំណែកព្រះអម្ចាស់យេស៊ូវដែលទ្រង់ជាមហាក្សត្រយាងមកគ្រប់គ្រងពិភពលោកយើងនេះ មានលក្ខណៈដោយឡែកពីអ្នកដឹកនាំគ្រប់រូបដែលធ្លាប់គ្រប់គ្រងសកលលោក ទោះបីសម័យអតីតកាល សម័យបច្ចុប្បន្ន និងសម័យអនាគតក្តី។ រាជ្យរបស់ព្រះអម្ចាស់យេស៊ូវ ទ្រទ្រង់ដោយធម៌ត្រៃសិលា គឺសេចក្តីពិត១ សេចក្តីសុភាព១ និងសេចក្តីសុរិត១។ មនុស្សលោកតែងចោទប្រកាន់ព្រះអម្ចាស់យេស៊ូវថា ទ្រង់ជាជនភូតភរ តែតាមពិតមនុស្សលោកទេតើ ជាអ្នកភូតភរ។ សព្វថ្ងៃនេះ សូមសង្កេតមើលចុះ ទោះបីប្រព័ន្ធពត៌មាន ទោះបីច្បាប់រដ្ឋសភា ច្បាប់រដ្ឋាភិបាល ច្បាប់សេដ្ឋកិច្ច ច្បាប់តុលាការ រឿងភូតភរជារឿងធម្មតាសម្រាប់កិច្ចការរបស់គេ។ ប៉ុន្តែយើងមិនគួរបន្ទោសដល់លោកទាំងនោះទេ ពីព្រោះលោកទាំងនោះប្រៀបឧបមាដូច

ជាអណ្ដូងគ្មានបាត។ សព្វថ្ងៃ មនុស្សដែលយើងគួរបន្ទោស គឺក្រុមជំនុំរបស់ព្រះជាម្ចាស់។ ក្រុមជំនុំខ្លះរបស់ព្រះជាម្ចាស់ តាំងនៅដាច់ពីធម៌ទាំងបី គឺសេចក្ដីពិត១ សេចក្ដីសុភាព១ និងសេចក្ដីសុចរិត១។ រាជ្យរបស់ព្រះអម្ចាស់យេស៊ូវគ្រិស្ដផ្ទាល់ ប្រកបដោយធម៌ទាំងបីយ៉ាងនោះ។ ពេលព្រះអម្ចាស់យេស៊ូវយាងមកគ្រប់គ្រងលើផែនដី ព្រះអង្គគ្រប់គ្រងពេញដោយសេចក្ដីពិត១ សេចក្ដីសុភាព១ និងសេចក្ដីសុចរិត១។

> **ព្រួញទ្រង់មុតជៀបដល់បេះដូងរបស់ពួកខ្មាំងសត្រូវនៃព្រះករុណា សាសន៍ទាំងប៉ុន្មាននឹងដួលចុះនៅក្រោមទ្រង់ (ទំនុកដំកើង ៤៥:៥)។**

សេចក្ដីពិតដែលសម្ដែងនៅក្នុងខខាងលើ បញ្ជាក់ពីព្រះរាជបុគ្គលិកលក្ខណៈរបស់ព្រះមហាក្សត្រ ដែលត្រូវយាងមកគ្រប់គ្រងពិភពលោកយើងនេះ។ ព្រះនាមទ្រង់ គឺព្រះអម្ចាស់យេស៊ូវគ្រីស្ទ។

## រាជ្យនៃព្រះអង្គសង្គ្រោះ

ខខាងក្រោមនេះ សម្ដែងពីការឡើងគ្រងរាជ្យនៃព្រះមហាក្សត្រ ដែលយាងមកតាំងរាជ្យរបស់ទ្រង់នៅលើផែនដី។

**ឱព្រះអង្គអើយ បល្ល័ង្កទ្រង់ស្ថិតស្ថេរនៅអស់កល្បជានិច្ចរៀងរាបតទៅ ឯព្រះដំបងពេជ្ររបស់រាជ្យទ្រង់ នោះជាដំបងសុចរិត (ទំនុកដំកើង៤៥:៦)។**

ព្រះអម្ចាស់យេស៊ូវគ្រីស្ទ យាងមកគ្រប់គ្រងសកលលោកយើងនេះ ប្រកបដោយសេចក្ដីសុចរិត។ ពិភពលោកត្រូវការអ្នកដឹកនាំដែលមានសេចក្ដីសុចរិតក្នុងខ្លួន។ ទាក់ទងនឹងការយាងត្រឡប់មកវិញនៃព្រះអម្ចាស់យេស៊ូវ ដើម្បីគ្រប់គ្រងសកលលោកយើងនេះ ព្រះអង្គមានបន្ទូលពីព្រះឱស្ឋទ្រង់ផ្ទាល់ថា "តែកាលណាកូនមនុស្សនឹងមកក្នុងសិរីល្អរបស់លោក មានទាំងពួកទេវតាបរិសុទ្ធទាំងអស់គ្នា មកជាមួយ នោះលោកនឹងឡើងគង់លើបល្ល័ង្ករុងរឿងឧត្ដមរបស់លោក" (ម៉ាថាយ២៥:៣១)។ នៅលើលោកនេះ សេចក្ដីសុខសាន្ដមានពេញលេញទាល់តែព្រះអម្ចាស់យេស៊ូវ យាងមកតាំងរាជ្យរបស់ទ្រង់នៅលើផែនដីយើងទាំងមូល។ រាជ្យនានានឹងត្រូវសាបសូន្យ តែរាជ្យរបស់ព្រះជាម្ចាស់នឹងត្រូវស្ថិតស្ថេរនៅអស់កល្បជានិច្ច។ ព្រះអង្គគ្រងរាជ្យដោយព្រះចេស្ដារបស់ទ្រង់ រាជ្យរបស់ទ្រង់ប្រកបដោយសេចក្ដីពិត១ សេចក្ដីសុភាព១ និងសេចក្ដីសុចរិត១ អស់កល្បជានិច្ចតរៀងទៅ។

**ទ្រង់បានស្រឡាញ់សេចក្ដីសុចរិត ហើយស្អប់ការទុច្ចរិត ហេតុនោះបានជាព្រះ គឺជាព្រះនៃទ្រង់ បានចាក់ប្រេងថ្វាយទ្រង់ ជា**

**ប្រេងនៃសេចក្តីត្រេកអរសាទរ លើសជាងពួកសំឡាញ់នៃទ្រង់ (ទំនុកដំកើង៤៥:៧)។**

អង្គដែលព្រះជាម្ចាស់ចាក់ប្រេងថ្វាយទ្រង់ គឺអង្គព្រះគ្រីស្ទ។ នៅក្នុងភាសាក្រេក ពាក្យថា "គ្រីស្ទ" មានន័យថា អង្គដែលព្រះជាម្ចាស់ចាក់ប្រេងតាំងថ្វាយទ្រង់។ ព្រះគ្រីស្ទមិនមែនជានាមរបស់ទ្រង់ទេ គឺគ្រាន់តែជាតួនាទីរបស់ទ្រង់ប៉ុណ្ណោះ។ កាលទ្រង់យាងមកជាលើកទីមួយ ទ្រង់យាងមកបំពេញតួនាទីជាហោរា ពោលគឺជាអ្នកនាំដំណឹងល្អនៃសេចក្តីសង្គ្រោះពីព្រះជាម្ចាស់ មកដល់មនុស្សលោកមានបាប។ គ្រានោះជាគ្រានៅក្នុងអតីតកាល។ គ្រាបច្ចុប្បន្ន ព្រះអម្ចាស់យេស៊ូវបំពេញតួនាទី ជាសង្ឃដ៏ខ្ពស់បំផុត។ ទ្រង់អធិស្ឋានទូលអង្វរជំនួសរាស្ត្របរិសុទ្ធរបស់ទ្រង់។ សព្វថ្ងៃ ព្រះអម្ចាស់យេស៊ូវកំពុងគង់នៅទីខាងស្តាំនៃបល្ល័ង្ករបស់ព្រះវរបិតា។ គ្រានេះ គឺជាគ្រាបច្ចុប្បន្ន។ ចំណែកនៅគ្រាអនាគតវិញ ព្រះអម្ចាស់យេស៊ូវយាងត្រឡប់មកផែនដីជាលើកទីពីរ ក្នុងនាមទ្រង់ជាមហាក្សត្រ និងជាអង្គដែលរំដោះរាស្ត្រអ៊ីស្រាអែលសេសសល់ អោយរួចពីការជិះជាន់ក្នុងគ្រាមហាទុក្ខ។ ហេតុការណ៍នោះកើតឡើងនៅក្នុងគ្រាអនាគត។

"គឺជាព្រះនៃទ្រង់បានចាក់ប្រេងថ្វាយទ្រង់ ជាប្រេងនៃសេចក្តីត្រេកអរសាទរ"។ យើងចេះតែគិតថា ពេលព្រះអម្ចាស់យេស៊ូវយាងមកលើផែនដី ដើម្បីដោះបាបមនុស្សលោក ទ្រង់ជាមនុស្សដែលពោរពេញដោយសេចក្តីទុក្ខព្រួយ។ រឿងនេះមិនពិតទេ។ ព្រះគម្ពីរបានសម្តែងថា ព្រះអង្គយាងមកទទួលការចាក់ប្រេងតាំងផ្តល់

សេចក្ដីសង្គ្រោះដល់មនុស្សលោក។ ទ្រង់យាងមកទទួលការចាក់ប្រេងតាំងដោយសេចក្ដីត្រេកអរសាទរ។

ទំនុកតំកើងជំពូក៤៥ ជាបទទំនាយពីព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ គម្ពីរហេព្រើរ ១:៨-៩ ពន្យល់រឿងនេះអោយបានពិស្ដារថា "តែខាងឯព្រះរាជបុត្រាវិញ នោះទ្រង់មានបន្ទូលថា "ឱព្រះអើយ បល្ល័ង្កទ្រង់នៅជាប់អស់កល្បជានិច្ចរៀងរាបតទៅ ព្រះដំបងពេជ្ររបស់រាជ្យទ្រង់ នោះជាដំបងសុចរិត ទ្រង់បានស្រឡាញ់សេចក្ដីសុចរិត ហើយស្អប់ការទទឹងច្បាប់ ហេតុនោះបានជាព្រះ គឺជាព្រះនៃទ្រង់បានចាក់ប្រេងថ្វាយទ្រង់ ជាប្រេងនៃសេចក្ដីត្រេកអរសាទរលើសជាងពួកសំឡាញ់នៃទ្រង់"។ សេចក្ដីនេះ មិនមែនចែងពីស្ដេចសាឡូម៉ូនទេ ពីព្រោះស្ដេចសាឡូម៉ូនជាស្ដេចទទួលបរាជ័យដែរ។ ខនេះសម្ដែងពីព្រះអម្ចាស់យេស៊ូវគ្រីស្ទ ដែលទ្រង់ជាព្រះផង ជាមហាក្សត្រផង។ ព្រះអង្គទ្រង់ជាព្រះ ដែលយាងមកពេញដោយសិរីល្អ ទ្រង់ជាព្រះ ជាតួនៃព្រះវរបិតា។ ទ្រង់មានតួនាទីខ្ពស់ជាងទេវតានានា។ ទ្រង់គង់នៅខាងស្ដាំនៃបល្ល័ង្ករបស់ព្រះវរបិតា។

**ព្រះពស្ត្រទ្រង់ផ្សាយក្លិនក្រអូប ដោយជ័រល្វីងទេសក្រឹស្នា នឹងកំញាន មានឮសូរភ្លេង ចេញពីដំណាក់ភ្លុក បណ្ដាលឱ្យទ្រង់សប្បាយឡើង (ទំនុកដំកើង៤៥:៨)។**

ព្រះអម្ចាស់យេស៊ូវគ្រីស្ទយាងមកផែនដី ដើម្បីធ្វើអោយសេចក្ដីអំណររបស់

យើងបានពេញជាបរិបូរ។ “ព្រះពស្ត្រទ្រង់ផ្សាយក្លិនក្រអូប ដោយជ័រល្វីងទេសក្រឹស្នា នឹងកំញាន មានឮសូរភ្លេង ចេញពីដំណាក់ភ្លុក បណ្ដាលឱ្យទ្រង់សប្បាយឡើង”។ ពេលទ្រង់ទទួលទោសជំនួសយើងនៅលើឈើឆ្កាង ព្រះអង្គទទួលទោសពេញដោយសេចក្ដីរីករាយ។ យើងជាអ្នកជឿដល់ព្រះអម្ចាស់ ត្រូវការមានសេចក្ដីរីករាយសប្បាយ។ កុលសម្ព័ន្ធសាសន៍យូដា ដែលមានន័យថាសរសើរ នាំមុខសាសន៍អ៊ីស្រាអែលដើរកាត់ទីរហោស្ថាន។ ផ្ទុយពីឈ្មោះរបស់គេ គេមិនបាននាំការសសើរដល់ព្រះជាម្ចាស់ទេ។ ពេលគេជួបនឹងទុក្ខលំបាកក្នុងទីរហោស្ថាន គេនាំគ្នាស្រែកច្រៀងបទចម្រៀងមួយដែលមានចំណងជើងថា “មេឃខ្មៅងងឹត”។ បទពិសោធន៍ប្រភេទនេះ ក្រុមជំនុំរបស់ព្រះជាម្ចាស់ ក៏ជួបប្រទះនឹងរឿងបែបដូច្នេះដែរ។ យើងជាគ្រីស្ទបរិស័ទ យើងត្រូវសរសើរតម្កើងព្រះជាម្ចាស់។ យើងមិនត្រូវចេះតែបើកមាត់ឡើងរអ៊ូរទាំទាស់នឹងព្រះអង្គ ទាស់នឹងអ្នកដឹកនាំការងារព្រះអង្គ ដូចអ្នកជឿខ្លះតែងមានទម្លាប់ធ្វើនោះទេ។ ម្យ៉ាងវិញទៀត បទចម្រៀងដែលមានចំណងជើងថា “អំណរដល់លោកព្រះបុត្រកើតហើយ” មិនត្រូវយកមកច្រៀងតែពេលធ្វើបុណ្យណូអែលប៉ុណ្ណោះទេ គឺត្រូវច្រៀងសម្រាប់សម្លឹងមើលទៅរាជ្យដែលព្រះអម្ចាស់យេស៊ូវយាងត្រឡប់មកវិញផងដែរ។

មិនតែប៉ុណ្ណោះ គម្ពីរទំនុកដំកើងជំពូក៤៥ បរិយាយពីសេចក្ដីពិតមួយផ្សេងទៀត។

**មានបុត្រីស្តេច នៅក្នុងពួកស្ត្រីជាន់ខ្ពស់របស់ទ្រង់ ឯអគ្គមហេសី ព្រះនាងគង់នៅខាងស្តាំទ្រង់ ប្រដាប់ដោយគ្រឿងមាសពីស្រុកអូភារ (ទំនុកដំកើង៤៥:៩)។**

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ មិនមានប្រើពាក្យក្រុមជំនុំទេ។ ប៉ុន្តែ ពាក្យក្រុមជំនុំ ត្រូវប្រើជាសំនួនវោហារស័ព្ទដូចជាកូនក្រមុំវិញ។ ពាក្យកូនក្រមុំនៅក្នុងព្រះគម្ពីរសញ្ញាចាស់និយាយសំដៅទៅកាន់ក្រុមជំនុំ ដែលព្រះអម្ចាស់យេស៊ូវបានទិញដោយព្រះលោហិតរបស់ទ្រង់។ ខខាងលើសម្តែងពីក្រុមជំនុំរបស់ព្រះជាម្ចាស់។ ព្រះអម្ចាស់យេស៊ូវលើកក្រុមជំនុំរបស់ព្រះអង្គ ដែលរស់នៅក្នុងគ្រាសញ្ញាចាស់ ដូចជាព្រះអង្គលើកក្រុមជំនុំរបស់ទ្រង់ ដែលរស់នៅគ្រាព្រះគម្ពីរសញ្ញាថ្មីដែរ។

**កូនស្រីអើយ ចូរស្តាប់ ហើយពិចារណា ចូរផ្ទៀងត្រចៀកស្តាប់ចុះ ចូរភ្លេចសាសន៍ឯង នឹងផ្ទះឪពុកឯងទៅ (ទំនុកដំកើង៤៥:១០)។**

យើងជាអ្នកជឿដល់ព្រះអម្ចាស់យេស៊ូវ ត្រូវលះចាកចេញពីលោកីយ៍នេះនៅថ្ងៃណាមួយជាមិនខាន។ ដូច្នេះ យើងមិនត្រូវបោះយុថ្កានាវាជីវិតយើងអោយជាប់នៅក្នុងលោកកីយ៍នេះទេ។ យើងបានទទួលការសង្គ្រោះរួចពីសេចក្តីប៉ងប្រាថ្នារបស់លោកីយ៍ហើយ។ ដូច្នេះ យើងចាំបាច់ត្រូវតោងអោយជាប់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។

**នោះស្តេចទ្រង់នឹងគាប់ព្រះទ័យ ដោយសេចក្តីលំអរបស់ឯង ដ្បិតទ្រង់ជាចៅហ្វាយឯង ដូច្នេះត្រូវកោតខ្លាចដល់ទ្រង់ (ទំនុកដំកើង ៤៥:១១)។**

ក្រុមជំនុំរបស់ព្រះអង្គ ប្រៀបឧបមាដូចជាកូនក្រមុំ ពីព្រោះព្រះអង្គបានលាងសម្អាតអំពើបាបរបស់ក្រុមជំនុំឥតមានប្រឡាក់អ្វីទៀត។ សូមលោកអ្នកយល់អោយបានច្បាស់ថា ទោះបីក្រុមជំនុំរបស់ព្រះអង្គ មើលទៅហាក់ដូចជាមានភាពស្មោគគ្រោកមែន តែចំពោះព្រះនេត្ររបស់ព្រះអង្គ ទ្រង់រាប់ថា ក្រុមជំនុំឥតមានប្រឡាក់ស្នាម ឬជ្រីវជ្រួញអ្វីឡើយ។ ក្រុមជំនុំមានឯកសិទ្ធិបែបនេះ ពីព្រោះព្រះអម្ចាស់យេស៊ូវ បានលាងសំអាតអំពើបាបរបស់គេរួចហើយ។

**អញនឹងធ្វើឱ្យមានសេចក្តីរឭកនឹកចាំពីឈ្មោះឯង នៅគ្រប់ទាំងដំណមនុស្សតទៅ ហេតុនោះអស់ទាំងសាសន៍នឹងសរសើរដល់ឯង នៅអស់កល្បជានិច្ចរៀងរាបតទៅ (ទំនុកដំកើង៤៥:១៧)។**

ខខាងលើសម្តែងពីរាជ្យមួយពាន់ឆ្នាំ ដែលព្រះអម្ចាស់យេស៊ូវគ្រីស្ទយាងមកសោយរាជ្យ។ រាជ្យមួយពាន់ឆ្នាំត្រូវមានរហូតអស់កល្បជានិច្ច។ ប៉ុន្តែ បន្ទាប់ពីគ្រាមួយពាន់ឆ្នាំ ព្រះជាម្ចាស់បានលែងសាតាំងអោយធ្វើការវា មុននឹងទ្រង់ចាប់វាបោះទៅក្នុង

បឹងភ្លើង។

គម្ពីរទំនុកដំកើងដែលយើងបានសិក្សាក្នុងថ្ងៃនេះ មានសេចក្ដីពិតបង្កប់យ៉ាងជ្រាលជ្រៅអស្ចារ្យ។ យើងចាំបាច់ត្រូវយល់ពីខ្លឹមសារនៃបទគម្ពីរទាំងនេះ ទើបយើងអាចយកអត្ថន័យ មកអនុវត្តនៅក្នុងជីវិតរបស់យើងយ៉ាងមានប្រសិទ្ធភាពជារៀងរាល់ថ្ងៃបាន។

យើងស្លេះការសិក្សាគម្ពីរទំនុកដំកើងត្រឹមណេះសិនចុះ។ ទំរាំយើងជួបគ្នាលើកក្រោយ សូមព្រះជាម្ចាស់ប្រទានពរដ៏ធំឧត្តម ដល់លោកអ្នកបងប្អូនគ្រប់ៗគ្នា។ "ដើរជាមួយនឹងព្រះ ពិតជាប្រទះនឹងព្រះយេស៊ូវជាមិនខាន!"